# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2012, 16:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើអនុលោមតាមវិធាន ៣៥ សុំឲ្យមានចំណាត់ការ
# ជាបន្ទាន់ប្រឆាំងនឹងរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Joshua ROSENSWEIG

ផ្ញើជូន៖

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang
Elisabeth SIMONNEAU-FORT

## I. សេចក្ដីផ្ដើម

១. អនុលោមទៅតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (វិធាន)[1] មេធាវីការពារជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្ដី") តទៅនេះសូមដាក់សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំង **ហោ ណាំហុង** រដ្ឋមន្ត្រីការបរទេសប្រទេសកម្ពុជា។ សម្រាប់មូលហេតុទាំងអស់ដែលបញ្ជាក់នៅខាងក្រោម មេធាវីការពារក្ដី ស្នើសុំឱ្យពិចារណាថា: (ក) សំណើនេះអាចទទួលយកបាន (ខ) ការកត់សម្គាល់នាពេលថ្មីៗនេះដោយ **ហោ ណាំហុង** នៅក្នុងសារព័ត៌មានកម្ពុជា ដែលត្រូវបានគេយល់ឃើញថាជាការប៉ុនប៉ងមួយដើម្បីមានឥទ្ធិពលទៅលើអង្គជំនុំជម្រះសាលាដំបូង សាក្សីដែលនឹងផ្ដល់សក្ខីកម្មជាបន្តបន្ទាប់ ក្រុមមេធាវីការពារក្ដី ព្រមទាំងមហាជនទូទៅ បង្កើតបានជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់ អវតក និង(គ) អង្គជំនុំជម្រះសាលាដំបូង ត្រូវតែផ្ដល់ដំណោះស្រាយមួយដែលមានប្រសិទ្ធភាព និងអាចអនុវត្តបាន។ ដោយសារបញ្ហានេះជាបញ្ហាបឋម មេធាវីការពារក្ដីប្រកាន់ជំហាថា សំណើនេះត្រូវតែចំណាត់ថ្នាក់ជាឯកសារសាធារណៈ ឱ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន ដោយសារវាទាក់ព័ន្ធទៅនឹងសកម្មភាពនានាដែលប៉ះពាល់ដោយផ្ទាល់ និងបន្ទាន់ទៅលើសុច្ចរិកភាពរបស់ អវតក ។ ពិចារណាពីបញ្ហាដែលលើកឡើងនៅក្នុងសំណើនេះ សំណើនេះត្រូវតែបានជូនដំណឹងដល់សាធារណជនឱ្យបានទូលំទូលាយដោយមិនបង្អង់[2]។

## II. អង្គហេតុពាក់ព័ន្ធ

២. អង្គហេតុក្នុងសំណើនេះ គឺមានលក្ខណៈចំៗ ។ នៅថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១២ **ហោ ណាំហុង** ចេញសេចក្ដីថ្លែងការណ៍ដូចខាងក្រោម[3] (សេចក្ដីថ្លែងការណ៍):

---

[1] សូមមើលវិធានផ្ទៃក្នុង អវតក (វិសោធនកម្មលើកទី៨) ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១ ។

[2] កំណត់សំគាល់: ជាដំបូងក្រុមមេធាវីការពារក្ដីប៉ុនប៉ងលើក *ជាសាធារណៈ*នៅចំពោះអង្គជំនុំជម្រះអំពីផលប៉ះពាល់នៃសេចក្ដីថ្លែងការណ៍នេះ ។ ប៉ុន្តែមេក្រូហ្វូនរបស់មេធាវីការពារក្ដីត្រូវបានកាត់ផ្ដាច់ (នៅពេលនេះ បទដ្ឋានអនុវត្តមួយ)ប្រធានអង្គជំនុំជម្រះបានប្រាប់មេធាវីការពារក្ដីឱ្យដាក់ជាបន្ទាន់នូវសំណើរបស់ខ្លួនជាលាយលក្ខណ៍អក្សរ "[...] "ពង្រាងប្រតិចារិតនៃថ្ងៃសវនាការ" ទី៦ ខែសីហា ឆ្នាំ២០១២ (សវនាការលើកទី៩០ នៅទំព័រ៣៥:២១) ។

[3] សូមមើលការអធិប្បាយខ្លីដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ (អាចរកបាននៅគេហទំព័រ http://cambodiainfo.or) ។

## មតិដ៏ខ្លីរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហោ ណាំហុង

> វាជារឿងអកុសលណាស់ អ្នកដែលបន្តការពារកេរដំណែលរបបខ្មែរក្រហម ខិតខំបង្វែរការយកចិត្តទុកដាក់ចេញពីកេរមរកតរបស់ខ្មែរក្រហម ក្នុងផលប្រយោជន៍នៃការការពាររបស់គេ ដោយបង្វែរទិសពីការយកចិត្តទុករឿងរបស់គេ ដោយបង្កហេតុឲ្យមានការយល់ច្រឡំមកលើឥស្សរជនសាធារណៈដូចជារូបខ្ញុំ ។ ខ្ញុំចង់និយាយយ៉ាងខ្លីពីប្រវត្តិរបស់ខ្ញុំ ដើម្បីជម្រះឲ្យអស់នូវការខ្វែងគំនិតទាំងនេះ ។ របបខ្មែរក្រហម គឺជារឿងសោកនាដកម្មមួយ ដែលនៅតែដត់ជាប់ក្នុងអារម្មណ៍ប្រជាជនកម្ពុជារហូតដល់សព្វថ្ងៃ ។ ក្នុងនាមជាអ្នកទោសនៅជំរុំអប់រំបឹងត្របែក ដែលនៅទីនោះខ្ញុំបានបាត់បង់ប្អូនស្រីពីរនាក់ព្រមទាំងស្វាមី និងកូនរបស់គេ និងក្មួយស្រីម្នាក់ ក៏ដូចជាសហសេវិនជាច្រើន ខ្ញុំគ្មានអ្វីក្រៅពីការសោកសៅ និងការរំលែកទុក្ខលំបាករបស់ជនរងគ្រោះ និងក្រុមគ្រួសារគេ ។ សូម្បីតែមកដល់សព្វថ្ងៃនេះក្តី ក៏ប្រជាជនកម្ពុជានៅតែបន្តរងទុក្ខដោយសារឧក្រិដកម្មរបស់របបខ្មែរក្រហម ។ ពួកខ្មែរក្រហមមិនត្រឹមតែបានបំផ្លាញប្រជាជនខ្មែរអស់មួយជំនាន់នោះទេ តែក៏បានបំផ្លិតបំផ្លាញស្ទើរតែទាំងអស់ផងដែរនូវអរិយធម៌ខ្មែរ ដែលមកដល់ពេលនេះយើងកំពុងតែបន្តស្តារឡើងវិញ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការច្បាប់ មិនមែនជាវេទិការនយោបាយនោះទេ។ ខ្ញុំជឿជាក់ថា ការប៉ុនប៉ងធ្វើនយោបាយភាវូបនីយកម្មតុលាការនេះ ឬការបង្កឲ្យមានការខ្វែងគំនិតគ្នា គឺជាទង្វើមិនសមស្របទេ ។
>
> ការសង្ឃឹមដ៏ធំធេងរបស់ខ្ញុំ គឺថានៅថ្ងៃណាមួយ នឹងរកឃើញនូវយុត្តិធម៌ និងកេរដំណែលរបស់ខ្មែរក្រហម ដែលនឹងត្រូវបោះចោលទៅក្នុងធុងសំរាមប្រវត្តិសាស្ត្រ ដោយលែងមានអ្នកការពារ ឬការខ្វែងគំនិតគ្នាទៀត ។

ខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះត្រូវបានបោះពុម្ពផ្សាយទាំងស្រុងនៅក្នុងព្រឹត្តិបត្រ ឌឹភ្នំពេញប៉ុស្តនៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ២០១២[4]។ នៅថ្ងៃដដែលមួយផ្នែកធំនៃសេចក្តីថ្លែងការណ៍នេះត្រូវបានចុះផ្សាយនៅក្នុងព្រឹត្តិបត្រ *Cambodia daily* ដែលបរិយាយស៊ីជម្រៅនៅក្នុងអត្ថបទមួយ ទាក់ទងនឹងការកត់

---

[4] សូមមើលការអធិប្បាយដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង *Phnom Penh Post* ចុះផ្សាយថ្ងៃទី៣ ខែសីហា ឆ្នាំ ២០១២ នៅទំព័រ៣ ។

សម្គាល់ជាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ[5]។ សេចក្តីថ្លែងការណ៍នេះត្រូវបានចុះផ្សាយយ៉ាងទូលំទូលាយនៅក្នុងសារព័ត៌មានភាសាខ្មែរនៃកាសែតក្នុងស្រុកជាច្រើនដែរ។ [6] ផ្អែកតាមព័ត៌មាន និងការជឿជាក់ ហោ ណាំហុង បានចេញសារមួយដែលមានខ្លឹមសារស្រដៀងនឹងសេចក្តីថ្លែងការណ៍នេះតាមវិទ្យុជាតិកម្ពុជា។

៣. សេចក្តីថ្លែងការណ៍នេះត្រូវបានចេញជាការឆ្លើយតបចំពោះការផ្តល់សក្ខីកម្មរបស់សាក្សី ភី ភួន (ហៅរ៉ូជាមតុន ហៅវីដាម) ដែលបានបញ្ជាក់នៅថ្ងៃទី ៣១ ខែ កក្កដាឆ្នាំ ២០១២ ថានៅចុងបញ្ចប់នៃរបបកម្ពុជា **ហោ ណាំហុង** គ្រប់គ្រងជំរុំអប់រំបឹងត្របែក[7]។

៤. ត្រូវបានគេដឹងនៅកម្ពុជាថា **ហោ ណាំហុង** បានប្រើបណ្តឹងបរិហារកេរ្តិ៍ជាយានដើម្បីបិទមាត់បុគ្គលសំខាន់ៗជាច្រើន មានជាអាទិ៍ សម្តេចឪ **នរោត្តម សីហនុ** និងមេដឹកនាំបក្សប្រឆាំង **សម រង្ស៊ី** ដែលបានពិភាក្សាជាសាធារណៈពីអតីតតួនាទីរបស់រដ្ឋមន្ត្រីការបរទេស និងសកម្មភាពនានានៅបឹងត្របែក។ គាត់សម្រេចបានជោគជ័យនូវកម្រិតមួយ[8]។

---

[5] សូមមើល Lauren Crothers, "ហោ ណាំហុង ថ្លែងពីការអះអាងអំពីបឹងត្របែក" ព្រឹត្តិបត្រ *the Cambodia daily* ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ (អត្ថបទ *the Cambodia daily)* នៅទំព័រ១។

[6] សូមមើល "កេរ្តិ៍តំណែលខ្មែរក្រហម ហោ ណាំហុង៖ ការធ្វើនយោបាយភាវូនីយកម្មតុលាការគឺជាទង្វើមិនសមស្រប" ដកស្រង់ចេញពីកាសែត កោះសន្តិភាព ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ "ហោ ណាំហុង បង្ហាញថាការចោទប្រកាន់មកលើគាត់គឺ អយុត្តិធម៌" ដកស្រង់ចេញពីកាសែត កម្ពុជាថ្មី ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ "ណាំហុង ចេញមុខបកស្រាយប្រវត្តិរូបរបស់គាត់ ពេលសាក្សីផ្តល់សក្ខីកម្មថាជាមេគុក បឹងត្របែក" ដកស្រង់ចេញពី *Free Press Magazine* ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។

[7] ពង្រាងប្រតិចារិតសវនាការ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ (សវនាការលើក៨៧) នៅទំព័រ៦៣:៥-៦ ។

[8] អត្ថបទរបស់កាសែត the Cambodia Daily ។ (នៅឆ្នាំ២០០៨ លោក ហោ ណាំហុង ប្តឹងមេដឹកនាំបក្សប្រឆាំង សម រង្ស៊ី នៅតុលាការប្រទេសបារាំង និងតុលាការកម្ពុជា ពីបទថាបានបរិហារកេរ្តិ៍គាត់នៅក្នុងសុន្ទរកថាមួយដែលអះអាងថា គាត់ជាប្រធានជំរុំបឹងត្របែក ។ លោក សម រង្ស៊ី ត្រូវបានតុលាការជាន់ទាបនៅប្រទេសទាំងពីររកឃើញថាមានទោស។ ប៉ុន្តែក្រោយមកតុលាការកំពូលប្រទេសបារាំងបានច្រានចោលសាលក្រមរបស់តុលាការជាន់ទាបរបស់ប្រទេសបារាំងនៅខែមេសា ឆ្នាំ២០១១។ លោក ហោ ណាំហុង បានឈ្នះបណ្តឹងលើសម្តេចឪ នរោត្តម សីហនុ នៅតុលាការប្រទេសបារាំងនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ លើបណ្តឹងស្រដៀងនេះ ។

៥. **ហោ ណាំហុង** ព្រមជាមួយមន្ត្រីជាន់ខ្ពស់ប្រាំរូបផ្សេងទៀតនៃរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ២០០៩ មិនព្រមចូលខ្លួនជាសាក្សីក្នុងសំណុំរឿង ០០២ តាមដីកាកោះរបស់សហចៅក្រមស៊ើបអង្កេត។ ខណៈក្រុមមេធាវីការពារក្តីបានស្នើជាច្រើនដង សុំឱ្យពួកគេផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពុំមានមន្ត្រីជាន់ខ្ពស់ណាម្នាក់នៃរដ្ឋាភិបាលកម្ពុជា មានគំរោងថានឹងផ្តល់ភស្តុតាងជាសក្ខីកម្មនៅក្នុងករណី **នួន ជា** ឡើយ ។ អង្គហេតុជុំវិញការជ្រៀតជ្រែកដែលមិនអាចអនុគ្រោះរបស់រដ្ឋាភិបាលជាផ្នែកនៃសំណុំរឿង និងជាបញ្ហានៃកំណត់ត្រាសាធារណៈ។ ដែលពុំសូវស្រុះសាយប៉ុន្មាននោះគឺអង្គហេតុដែលថាឈ្មោះ **ហោ ណាំហុង** បង្ហាញនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ជាច្រើនដង។ បន្ថែមពីលើនេះ កសចស បានលើកមកសំអាងសេចក្តីថ្លែងការណ៍មួយដែល **ហោ ណាំហុង** បានផ្តល់ឱ្យអ្នកធ្វើបទសម្ភាសន៍ម្នាក់នៅឆ្នាំ ១៩៩១ នៅទីក្រុង New York មិនតិចជាងប្រាំបីដងទេ ដើម្បីធ្វើជាបន្ទាល់ក្នុងការចោទប្រកាន់មកលើ នួន ជា។ សរុបមក **ហោ ណាំហុង** គឺជាសាក្សីសំខាន់មួយរូបសំរាប់សំណុំរឿង ០០២ ។

## III. **ច្បាប់ពាក់ព័ន្ធ**

៦. ពាក់ព័ន្ធទៅនឹងបញ្ហានៃការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការនៅ អវតក តទៅនេះ មេធាវីការពារក្តី សូមដាក់បញ្ចូលសេចក្តីសន្និដ្ឋានក្នុងសំណើរបស់ខ្លួនសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំង **ហ៊ុន សែន** អនុលោមតាមវិធាន៣៥ (“សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំង **ហ៊ុន សែន**”)[9] និងបណ្តឹងសារទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំង **ហ៊ុន សែន** អនុលោមតាមវិធាន៣៥ “បណ្តឹងសារទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំង **ហ៊ុន សែន**”[10]។

៧. ជាបទប្បញ្ញត្តិដ៏សំខាន់មួយដើម្បីការពារឯករាជ្យភាព និងអនាគតិរបស់ អវតក និងដើម្បីធានាបន្ថែមទៀតឱ្យមានការជំនុំជម្រះក្តីដ៏យុត្តិធម៌ជូនជនជាប់ចោទ វិធាន៣៥ នៃវិធានផ្ទៃក្នុង គឺពិតជាមានសារៈសំខាន់ណាស់ :

---

[9] សូមមើលឯកសារ **E-176**, 22 , ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00782947–00782959 កថាខណ្ឌទី៨ ដល់១៥។

[10] សូមមើលឯកសារ **E-176/2/1/1** ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២, ERN 00815298–00815309 កថាខណ្ឌទី៩។

វិធាន៣៥ ត្រូវបានដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុងជាយន្តការណ៍មួយដើម្បីថែរក្សាសុច្ចរិតភាពនៃដំណើរការតុលាការទាំងនៅក្នុងដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ។ សុច្ចរិតភាពនៃដំណើរការតុលាការត្រូវបានធានាតាមរយៈការអនុវត្តន៍វិធាននេះប្រកបដោយសុភវិនិច្ឆ័យនៅពេលដែល [...] អង្គជំនុំជម្រះយល់ឃើញថាទង្វើរបស់បុគ្គលម្នាក់បានគំរាមកំហែងដល់កិច្ចការរដ្ឋបាលរបស់តុលាការ។ ក្នុងការអនុវត្តន៍បញ្ញត្តិនេះ ទោះបីជាគ្មានការប៉ះពាល់ភ្លាមៗទៅលើ [...] សេចក្ដីសម្រេចតាមផ្លូវតុលាការក៏ដោយ ការអនុវត្តន៍វិធាននេះ គឺជាការរារាំងចំពោះអ្នកដទៃទៀតដែលមានចេតនាប្រើឥទ្ធិពលទៅលើដំណើរការតុលាការ។ វិធាននេះក៏បានបង្កើន ទំនុកចិត្តទាំងចំពោះបុគ្គលដែលបានធ្វើអត្ថាធិប្បាយ និងអ្នកដែលអាចពិចារណាផ្ដល់ភស្តុតាងថា [...] អង្គជំនុំជម្រះនឹងចាត់វិធានការណ៍ *ដោយគ្មានភាពស្ទាក់ស្ទើរ*ចំពោះអ្នកដែលចង់ទប់ស្កាត់ ឬជះឥទ្ធិពលទៅលើការជាប់ពាក់ព័ន្ធរបស់ពួកគេជាមួយនឹង អវតក។ ធ្វើដូច្នេះ ភាពអាចជឿជាក់បាននៃដំណើរការនីតិវិធីនៅចំពោះមុខ អវតក ទាំងនៅក្នុងកម្រិតជាតិ និងអន្តរជាតិ នឹងត្រូវបានថែរក្សា[11]។

៨. ជាងនេះទៅទៀត ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានអះអាងកាលពីមុនថា គោលបំណងនៃការហាមឃាត់ការប្រព្រឹត្តដោយចេតនាធ្វើឲ្យប៉ះពាល់ដល់កិច្ចការរដ្ឋបាលរបស់តុលាការ គឺដើម្បីធានាថាការអនុវត្តន៍យុត្តាធិការរបស់តុលាការមិនត្រូវបានរារាំង និងដើម្បីធានាថាមុខងារជាមូលដ្ឋានត្រូវបានការពារ។ ច្បាស់ណាស់ថា បញ្ហានេះតម្រូវឲ្យតួអង្គខាងក្រៅមិនត្រូវស្វែងរកដាក់ឥទ្ធិពលទៅលើចៅក្រមក្នុងតុលាការនេះ តាមរយៈការប្រព្រឹត្តក្នុងរបៀបមួយដែលអាចឲ្យគេយល់ថាជាការប៉ុនប៉ងធ្វើដូច្នេះ[12]។

---

[11] ឯកសារ **D-314/2/7**, "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងដីកាសម្រេចរបស់ កសចស លើសំណើសុំកោះហៅសាក្សី" ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ ERN 00527392–00527420 (សេចក្ដីសម្រេចលើសំណើសុំកោះហៅសាក្សី) កថាខណ្ឌទី៣៨ (គូសបញ្ជាក់បន្ថែម)។

[12] ឯកសារ **E-176/2** សេចក្ដីសម្រេចលើសំណើសុំឲ្យមានចំណាត់ការបន្ទាន់អនុលោមតាមវិធាន៣៥ ចុះថ្ងៃទី ១១ ខែ ឧសភាឆ្នាំ ២០១២ ERN 00806873–00806883 ("សេចក្ដីសម្រេចលើសំណើសុំឲ្យមានចំណាត់ការបន្ទាន់ប្រឆាំង ហ៊ុន សែន") កថាខណ្ឌទី២១។ កំណត់សំគាល់: នៅក្នុងបរិបទនេះ គេចាំបាច់ត្រូវតែរំលឹកអំពីការថ្លែងការជាសាធារណៈរបស់ចៅក្រម Cartwright ឆ្លើយតបទៅនឹងការអត្ថាធិប្បាយរបស់ **ហ៊ុន សែន** កាលពីឆ្នាំ២០០៩ : "សេចក្ដីអត្ថាធិប្បាយ ដោយមូលហេតុនយោបាយឬអ្វីផ្សេងទៀត ដែលហាក់បីដូចជាការប៉ុនប៉ងជ្រៀតជ្រែកចូលទៅក្នុងភាពឯករាជ្យរបស់តុលាការ ត្រូវតែថ្កោលទោស។ Maggie Tait ការជ្រៀតជ្រែក "ត្រូវបានថ្កោលទោស" ដោយចៅក្រម ដោយ Stuff New Zealand (NZPA), ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៩ (អាចរក

៩. បើគិតតាមតក្កវិជ្ជា ការអត្ថាធិប្បាយបែបនេះ គឺស្មើនឹងការប៉ុនប៉ងប្រើឥទ្ធិពលទៅលើសាក្សី មេធាវីការពារក្តី និង/ឬសាធារណៈជនទូទៅ ។

១០. ទាក់ទងនឹងការជះឥទ្ធិពលលើសាក្សី ឬអ្នកដែលនឹងអាចក្លាយជាសាក្សី អង្គបុរេជំនុំជម្រះបានសម្រង់សេចក្តីពីតុលាការ នៅក្នុងរឿងក្តីអគ្គព្រះរាជអាជ្ញា តទល់ Beqaj នៃតុលាការ ICTY:

> វាក្យសព្ទ "ការរំខានផ្សេងៗដល់សាក្សី ឬអ្នកដែលនឹងអាចក្លាយទៅជាសាក្សីណាមួយ" គឺជាការបញ្ជាក់បង្ហាញ ថាវិធាន ៧៧ ផ្តល់យ៉ាងពេញលេញនូវ បញ្ជីស្តីពី ទម្រង់នៃអំពើដែលជាការប្រមាថដល់តុលាការ។ ដោយពិចារណាលើធាតុផ្សំសត្យានុម័តដែលមានចែងនៅវិធាន ៧៧(ក) អង្គជំនុំជម្រះយល់ឃើញថា ការរំខានផ្សេងៗដល់សាក្សី រួមបញ្ចូលអំពើទាំងឡាយ ដែលបានប្រព្រឹត្តឡើងក្នុងគោលបំណងរំខានដល់កិច្ចរដ្ឋបាលតុលាការ ដោយជំរុញមិនឱ្យសាក្សីណាមួយ ឬអ្នកដែលនឹងក្លាយទៅជាសាក្សី ផ្តល់ភស្តុតាងពេញលេញ និងពិតប្រាកដ ឬដោយមធ្យោបាយផ្សេងទៀត ជះឥទ្ធិពលទៅលើលក្ខណៈនៃភស្តុតាងរបស់សាក្សី ឬអ្នកដែលនឹងក្លាយទៅជាសាក្សី ។ មិនមានការបង្ហាញណាមួយដែលតម្រូវឱ្យមានការបង្ហាញ ភស្តុតាងថា អំពើដែលបានប្រព្រឹត្តឡើងក្នុងគោលបំណងជះឥទ្ធិពលទៅលើលក្ខណៈនៃភស្តុតាងរបស់ សាក្សីបង្កើតបានទៅជាលទ្ធផលណាមួយនោះទេ[13] ។

## IV. **អំណះអំណាង**

## **ក. សំណើនេះអាចទទួលយកបាន**

១១. អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចជាក់លាក់ ក្នុងការដាក់ទណ្ឌកម្ម "ជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាល របស់អង្គជំនុំជម្រះ"[14]។ ការជ្រៀតជ្រែកបែបនេះត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយដោយវិធានផ្ទៃក្នុង ហើយត្រូវបានបកស្រាយយ៉ាងទូលំ

---

បាននៅ http://www.stuff.co.nz/world/asia/2315921 ការជ្រៀតជ្រែកត្រូវបានថ្កោលទោស ដោយចៅក្រម) (គូសបញ្ជាក់បន្ថែម)។

[13] ឯកសារ **D-314/1/12** "សេចក្តីសម្រេចលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីការបស់ កសចស ស្តីពីសំណើសុំកោះហៅសាក្សី" ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ ERN 00600748–00600774 នៅកថាខណ្ឌទី៣៤ (អក្សរក្នុងលេខយោងដើម លុបចោល)។

[14] វិធាន ៣៥(១)។

ទូលាយ ដោយយុត្តិសាស្ត្រដែលពាក់ព័ន្ធ[15]។ វិធាន៣៥ បានបញ្ចូលយ៉ាងច្បាស់ក្នុងវិសាលភាពរបស់ខ្លួននូវអត្តចរិកដែលបានសំដែងឡើងដោយលោករដ្ឋមន្ត្រីក្រសួងការបរទេស។ មិនតែប៉ុណ្ណោះ តុលាការជាន់ខ្ពស់ទាំងពីរនៃសាលាក្តីនេះ- អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់ថាភាគីអាចស្វែងរកដំណោះស្រាយវិជ្ជមានតាមរយៈបណ្តឹងរបស់ពួកគេ ដោយអនុលោមតាមវិធាន៣៥[16]។ ដូច្នេះ សំណើនេះអាចទទួលយកបាន ហើយអង្គជំនុំជម្រះសាលាដំបូងគួរតែដោះស្រាយវាដោយយកចិត្តទុកដាក់ ផ្អែកលើអង្គហេតុរបស់វា និងចេញសេចក្តីសម្រេចមួយដែលមានសំអាងហេតុពេញលេញ។

## ខ. ការអត្ថាធិប្បាយជាសាធារណៈរបស់ ហោ ណាំហុង គឺជាការរំលោភយ៉ាងច្បាស់ក្រឡែតទៅលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ

១២. សំណួរសំខាន់ក្នុងសំណើនេះ ថាតើការអត្ថាធិប្បាយជាសាធារណៈរបស់ **ហោ ណាំហុង** ឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវទាបបំផុតរបស់វិធាន ៣៥ ឬអត់នោះ ត្រូវតែមានការឆ្លើយតបជាវិជ្ជមាន[17]។ មន្ត្រីសាធារណៈសំខាន់ណាមួយ (“តំណាងឲ្យរដ្ឋ ឬអាជ្ញាធរសារធារណៈ) ដែលធ្វើសេចក្តីថ្លែងការណ៍ដូច **ហោ ណាំហុង** ទាក់ទងនឹងអង្គហេតុនានាដែលកំពុងតែពិចារណាដោយចៅក្រម និងជាកម្មវត្ថុនៃការស្តាប់សាក្សីដែលកំពុងអនុវត្តជាបន្តបន្ទាប់ដោយអង្គជំនុំជម្រះសាលាដំបូង គឺជាការជ្រៀកជ្រែតចូលក្នុងកិច្ចការរដ្ឋបាលមួយដែលត្រឹមត្រូវ ។ ក្នុងករណីនេះ វាចង្អុះបញ្ជាំងយ៉ាងច្បាស់ថា **ហោ ណាំហុង**

---

[15] សូមមើលកថាខណ្ឌទី៩ ដល់១០, ដូចជើងទំព័រខាងលើ។

[16] សូមមើលសេចក្តីសម្រេចលើសំណើសុំកោះហៅសាក្សី, កថាខណ្ឌទី៤៣ (ដោយអះអាងថា កសចស និងអង្គជំនុំជម្រះសាលាដំបូងមានអំណាចតាមផ្លូវច្បាប់ក្នុងចាត់វិធានការណ៍តាមឆន្ទានុសិទ្ធិ អនុលោមតាមវិធាន៣៥ ដោយមិនគិតពីលក្ខណៈដែលព័ត៌មានពាក់ព័ន្ធត្រូវបានដាក់នៅចំពោះមុខខ្លួន),ឯកសារ **E-116/1/6**, “សេចក្តីសង្ខេបសំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង ភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ”, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២, ឯកសារ ERN 00772881–00772887, កថាខណ្ឌទី១៧ (ដោយយល់ឃើញថាអង្គជំនុំជម្រះសាលាដំបូងមិនបានរារាំងមេធាវីការពារក្តីដោយមិនសមហេតុផលក្នុងការស្នើសុំដើម្បី ចាត់វិធានការណ៍ដោយឆន្ទានុសិទ្ធិ អនុលោមតាមវិធាន៣៥(២)។

[17] សូមមើលសំណើសុំឲ្យមានចំណាត់ការបន្ទាន់ប្រឆាំង ហ៊ុន សែន, កថាខណ្ឌទី៩។

ប្រព្រឹត្តដោយចេតនា និងដោយដឹងជាមុនថាអំពើរបស់គាត់ គឺរំខាន ឬ ជះឥទ្ធិ ពលមកលើសាក្សី ឬអ្នកដែលនឹងក្លាយទៅជាសាក្សី[18]។

១៣. ការលើកឡើងបែបនេះ គឺជាការត្រឹមត្រូវនៅក្នុងប្រព័ន្ធតុលាការ ឬនៅចំពោះមុខតុលាការផ្សេងៗ និងនៅគ្រប់ពេលទាំងអស់ៈ បើសិនជាការអធិប្បាយធ្វើឡើងដោយមន្ត្រីសាធារណៈក្នុងលក្ខណៈបើកចំហរបែបនេះ បង្កើតបានជាការជ្រៀកជ្រែតចូលក្នុងកិច្ចការរដ្ឋបាល ត្រឹមត្រូវរបស់តុលាការ[19]។ ក្នុងករណីនេះ បើពិចារណាពីតថភាពនៃកម្ពុជាបច្ចុប្បន្ន និងតួនាទី និងនៅមុនសកម្មភាពរបស់ **ហោ ណាំហុង** ទាក់ទងនឹងបញ្ហានេះ ការលើកឡើងនេះគឺពិតជាមានហេតុផលរឹងមាំ បើពិចារណាពីប្រវត្តិដែលបានកត់ត្រាទុកជាឯកសារយ៉ាងត្រឹមត្រូវអំពីការប៉ុនប៉ង ដោយកំរោលរបស់រដ្ឋមន្ត្រីក្រសួងការបរទេសដើម្បីបំបិទមាត់អ្នកណា ដែលបាននិយាយជាសាធារណៈទាក់ទងនឹងអតីតកាលរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះអ្នកសង្កេតការមិនលម្អៀងក្នុងប្រទេសនេះនឹងយល់ថាការថ្លែងបែបនេះ គឺជាការប៉ុនប៉ងដើម្បីធ្វើឲ្យមានឥទ្ធិពលទៅលើសាក្សីដែលនឹងផ្តល់សក្ខីកម្មជាបន្តបន្ទាប់ទៀតក្នុងសំណុំរឿង០០២ ទាក់ទងនឹងតួនាទីជាក់លាក់របស់ **ហោ ណាំហុង** នៅ ប-១ ។

១៤. ថា តើហោ ណាំហុង បានដឹង ឬមិនបានដឹងអំពីអង្គហេតុដែលថាការអធិប្បាយរបស់គាត់កើតឡើងព្រមគ្នានឹងការស្តាប់សក្ខីកម្មរបស់សាក្សីដទៃទៀត ដែលនឹងត្រូវកោះហៅឲ្យបំភ្លឺអំពីបញ្ហាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃមន្ទីរដែលហៅថា ប-១ (ក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ) និង ជុំវិញកែប្រែបឹងត្របែក គឺពុំច្បាស់នៅឡើយ ប៉ុន្តែជាលទ្ធផល គឺថាការអធិប្បាយជាសាធារណៈរបស់គាត់ គឺកាន់បង្កឲ្យមានការខូចខាតថែមទៀត ដោយសារតែថាសាក្សីដែលនឹងមកផ្តល់សក្ខីកម្មជាបន្តបន្ទាប់ នឹងកត់ត្រាទុកពីជំហររបស់ ហោ ណាំហុង ទាក់ទងនឹងបញ្ហានេះនៅមុនពួកគេមកផ្តល់សក្ខីកម្ម

---

[18] ជាការពិត (មិនមានការបង្ហាញណាមួយដែលតម្រូវឲ្យមានការបង្ហាញ ភស្តុតាងថា អំពើដែលបានប្រព្រឹត្តឡើងក្នុងគោលបំណងជះឥទ្ធិពលទៅលើលក្ខណៈនៃភស្តុតាងរបស់ សាក្សីបង្កើតបានទៅជាលទ្ធផលណាមួយនោះទេ) (កថាខណ្ឌទី៤៣ នៃសេចក្តីសម្រេចលើកទីពីររបស់ អបជ ដែលសម្រង់ចេញពីរឿងក្តីរដ្ឋអាជ្ញា តទល់ Bequaj) ។ម្យ៉ាងវិញទៀត បើតាមកត្តវិជ្ជា ដើម្បីឲ្យសំណើតាមវិធាន ៣៥ ទទួលបានជោគជ័យ គេមិនចាំបាច់កំណត់អត្តសញ្ញាណសាក្សីជាក់លាក់ណាមួយ ដែលអាចត្រូវបានបភ្លិចបំភ័យតាមរយៈធ្វើអធិប្បាយៈ ជនទាំងឡាយណាដែលនឹងក្លាយជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មទាក់ទងនឹងជុំវិញកែប្រែបឹងត្របែក ឬទាក់ទងនឹងតួនាទី ហោ ណាំហុង ក្នុងរបបខ្មែរក្រហម អាចប៉ះពាល់ជាអវិជ្ជមានដោយការអធិប្បាយរបស់ ហោ ណាំហុង ។

[19] ការជ្រៀកជ្រែតចូលក្នុងកិច្ចការរដ្ឋបាលតុលាការមិនចាំបាច់ថាត្រូវតែបានជោគជ័យ ឬសម្រេចបានលទ្ធផលណាមួយ ដែលបង្កើតបានជាការជ្រៀកជ្រែតចូលក្នុងកិច្ចការតុលាការនោះទេ បើពិចារណាពីខ្លឹមសារនៃវិធាន ៣៥ ។ សូមមើលកថាខណ្ឌទី១០ ។

។ បន្ថែមពីលើនេះ កត្តាដូចគ្នាទាំងនេះព្រមជាមួយតួនាទីដែលមិនអាចប៉ះបានជារដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជារបស់ ហោ ណាំហុង ត្រូវតែបានគេយល់ឃើញថា ជាការប៉ុនប៉ងមួយដើម្បីជះឥទ្ធិពលមកលើអង្គជំនុំជម្រះសាលាដំបូង ជាពិសេសភាពជាសមាជិកនៃចៅក្រមកម្ពុជា ដើម្បីបន្តបំបិទមាត់មេធាវីការពារក្តីលើបញ្ហានានាដែលរដ្ឋាភិបាលបច្ចុប្បន្នមិនពេញចិត្ត។ ជាងនេះទៅទៀត ការអធិប្បាយនេះ គឺជាការប៉ុនប៉ងច្បាស់ត្រង់ឡែក និងមិនអាចអនុគ្រោះឲ្យបាន ក្នុងការទាក់ទាញចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៃសំដីរបស់ ហោ ណាំហុង អំពីការសម្រេចអង្គហេតុនានាដែលកំពុងពិចារណាដោយតុលាការ។ ចំណុចនេះបង្កើតបានជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលត្រឹមត្រូវ ។

១៥. ពិតណាស់ សេចក្តីថ្លែងការណ៍នេះត្រូវតែបានពិចារណាផងដែរនៅក្នុងបរិបទឥរិយាបថផ្ទាល់ខ្លួនរបស់ **ហោ ណាំហុង** ពាក់ព័ន្ធនឹងដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ។ ហោ ណាំហុង មើលស្រាលដោយបើកចំហរ និងមានចេតនាពិតប្រាកដលើដីកាកោះហៅដែលមានសុពលភាពឲ្យមកបង្ហាញខ្លួននៅចំពោះមុខ កសចស ដើម្បីផ្តល់សក្ខីកម្ម។ ដូចអ្វីដែលចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះបានលើកឡើងយ៉ាងច្បាស់កាលពីមុនថា ពុំមានចៅក្រមដែលឥតលម្អៀងណាម្នាក់អាចខកខានមិនបានពិចារណា [កាលៈទេសៈនៅជុំវិញការបដិសេធមិនចូលខ្លួនរបស់រដ្ឋមន្ត្រីក្រសួងការបរទេស] បង្កើតបានជាហេតុផលដើម្បីឲ្យជឿជាក់ថា សមាជិកម្នាក់ ឬច្រើននាក់នៃរាជរដ្ឋាភិបាលកម្ពុជា ដោយដឹងជាមុន និងដោយចេតនា បានជ្រៀតជ្រែកសាក្សី ដែលអាចផ្តល់ភស្តុតាងនៅចំពោះ "សហចៅក្រមស៊ើបអង្កេតឡើយ[20]"។

១៦. ម្យ៉ាងវិញទៀត **ហោ ណាំហុង** គ្មានឆន្ទៈមកបង្ហាញខ្លួនចំពោះមុខ អវតក ដើម្បីរៀបរាប់ពីព្រឹត្តិការណ៍ដែលកំពុងស៊ើបអង្កេតឡើយ ទោះបីជាគាត់ត្រូវចងដោយកតាព្វកិច្ចផ្នែកច្បាប់ឲ្យធ្វើដូច្នេះក៏ដោយ។ ផ្ទុយទៅវិញ គាត់បែរជាធ្វើការរៀបរាប់ពីព្រឹត្តិការណ៍នោះតាមប្រព័ន្ធផ្សព្វផ្សាយទៅវិញ ដែលការធ្វើបែបនេះ គាត់មិនអាចត្រូវបានចោទសួរដោយភាគីឡើយ ហើយក៏អាចជះឥទ្ធិពលយ៉ាងខ្លាំងផងដែរ។ ការមិនមកបង្ហាញខ្លួនតាមការកោះហៅរបស់ចៅក្រម ហើយបន្ទាប់មក បន្តផ្តល់អត្ថាធិប្បាយសំខាន់ៗ

[20] ឯកសារ **D-314/1/12**, "សេចក្តីសម្រេចលើកទី២លើបណ្តឹងរបស់ អៀង សារី និង នួន ជាប្រឆាំងនឹងដីការបស់ កសចស សុំកោះហៅសាក្សី ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០", ឯកសារ, ERN 00600748–00600774 (យោបល់ដាច់ដោយឡែករបស់ចៅក្រម Catherine Marchi-Uhel និងចៅក្រម Rowan Downing), កថាខណ្ឌទី៦។

តាមប្រព័ន្ធផ្សព្វផ្សាយលើរឿងក្តីដែលកំពុងជំនុំជម្រះ គឺជាការជ្រៀតជ្រែកយ៉ាងច្បាស់ក្រឡែតក្នុងកិច្ចការរដ្ឋបាលតុលាការដ៏ត្រឹមត្រូវ។

១៧. កត្តាពាក់ព័ន្ធបន្ថែមទៀត នៅពេលយើងគិតពីការអត្ថាធិប្បាយទាំងនេះ គឺថាវាស៊ីសង្វាក់គ្នាខ្លាំងណាស់ទៅនឹងគំរូដែលបានបង្កើតឡើងនាពេលបច្ចុប្បន្ន ពោលគឺរាល់ពេលដែលមានអ្វីមួយកើតឡើងនៅអវតក ដែលរាជរដ្ឋាភិបាលកម្ពុជាមិនពេញចិត្ត រដ្ឋាភិបាលនេះនឹងបញ្ចេញប្រតិកម្មភ្លាមៗ។ ករណីនេះត្រូវបានគេសង្កេតឃើញនៅពេលដែលមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា៦រូប ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ កោះហៅឱ្យមកផ្តល់សក្ខីកម្ម ហើយវាក៏អាចត្រូវបានគេសង្កេតឃើញផងដែរនៅពេលដែលសហព្រះរាជអាជ្ញា និងសហចៅក្រមអន្តរជាតិ ប៉ុនប៉ងចោទប្រកាន់បុគ្គលបន្ថែមទៀតក្នុងសំណុំរឿង ០០៣ និង០០៤ ហើយគេក៏អាចសង្កេតឃើញក្នុងអំឡុងសវនាការលើអង្គសេចក្តីនៅពេលដែលអង្គហេតុ ត្រូវលើកយកមកពិភាក្សាដែលធ្វើឱ្យអាម៉ាស់ដល់មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន[21]។ ការពិតដែលថា ការថ្លែងទាំងនេះបង្កើតបានជាផ្នែកមួយនៃឥរិយាបថរបស់

---

[21] *កំណត់សម្គាល់* មុននេះមានការឆ្លើយតបយ៉ាងឆាប់រហ័សពីរដ្ឋាភិបាលទាក់ទងទៅនឹងអង្គហេតុកំពុងជំនុំជម្រះនៅពេលដែល ជា ស៊ីម និង ហេង សំរិន ត្រូវបានឆ្លើយដាក់ក្នុងរបាយការណ៍មួយរបស់លោក Stephen Heder ដែលត្រូវបានលើកយកមកពិភាក្សាក្នុងអំឡុងពេលជំនុំជម្រះកាលពីខែកុម្ភៈ ឆ្នាំ២០១២។ Jasper Pauw មេធាវីការពារក្តី នួន ជា បានដកស្រង់អត្ថបទមួយកាលពីឆ្នាំ២០០៥ របស់អ្នកប្រវត្តិវិទូ Stephen Heder ដែលបានចោទប្រកាន់ថា កងទ័ពក្រោមការបញ្ជារបស់លោក សំរិន បានសម្លាប់ជនស៊ីវិលវៀតណាម ក្នុងការវាយប្រហារកាត់ព្រំដែនក្នុងឆ្នាំ១៩៧៧ និងថាលោក ជា ស៊ីម ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់ប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុង និងមនុស្សមួយចំនួនទៀតក្នុងស្រុកពញាក្រែក ក្នុងខេត្តកំពង់ចាម។ លោក Koam Kosal ប្រធានខុទ្ទកាល័យលោក ហេង សំរិន បាននិយាយថា៖ "សម្តេចប្រធានជាអ្នកជួយសង្គ្រោះប្រជាជនចេញពីរបបខ្មែរក្រហម ប៉ុន្តែម៉េចបានជាគាត់ ត្រូវបានគេចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទៅវិញ? ខ្ញុំមិនយល់សោះ"។ លោក Kosal ***បានច្រានចោល***រាល់ការចោទប្រកាន់ទាំងអស់នៅក្នុងតុលាការប្រឆាំងលោក សំរិន ហើយបានសម្តែងពីភាពខ្វាយខ្វល់ទាក់ទងនឹងបញ្ហាថាតើហេតុអ្វីបានជាវាត្រូវបានលើកឡើងជាបញ្ហាសំខាន់នៅសាលាក្តីខ្មែរក្រហម។ លោក ជាម យៀប តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានអះអាងថា វាគ្មានអ្វីប្លែកទេដែលកាលនោះលោក ស៊ីម និង លោក សំរិន ជាសមាជិកខ្មែរក្រហម ប៉ុន្តែ***គ្មានពួកគាត់ណាម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ***។ លោក យៀប បានបន្ថែមទៀតថា "***ពួកគាត់មិនមែនជាសមាជិកជាន់ខ្ពស់***។ ***នៅពេលដែលពួកគាត់ដឹងថាបក្សសម្លាប់ប្រជាជន ពួកគាត់ បានចាកចេញពីបក្ស***"។ លោក ផៃ ស៊ីផាន អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានអះអាងថាតុលាការអាចចោទប្រកាន់តែមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដូចជា នួន ជា ដែលកំពុងជំនុំជម្រះ

រដ្ឋាភិបាលកម្ពុជា និងបានគាំទ្រយ៉ាងច្បាស់ក្រឡែត និងជាបន្តបន្ទាប់ដល់គំរូនៃឥរិយាបថមិនត្រឹមត្រូវរបស់រដ្ឋាភិបាល (នៅពេលមួយដែលគេអាចនិយាយបានថាទាក់ទងនឹងរឿងព្រហ្មទណ្ឌ[22]) គួរតែបានផ្តល់ហេតុផលបន្ថែមទៀតដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការថ្កោលទោសទង្វើបែបនេះ ។

១៨. សំអាងហេតុដូចគ្នានេះ ត្រូវយកមកអនុវត្តចំពោះការចាត់ទុករបស់ **ហោ ណាំហុង** ចំពោះយុទ្ធសាស្ត្ររបស់មេធាវីការពារក្តីថាជា "ការបង្កឲ្យមានភាពចម្រូងចម្រាស" ខណៈពេលដែលអ្វីៗគ្រប់យ៉ាងដែលមេធាវីការពារក្តីកំពុងធ្វើ គឺជាការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវទាំងស្រុងនូវរចនាសម្ព័ន្ធចាត់តាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាការវាយតម្លៃអំពីកម្រិត ឬការទទួលខុសត្រូវ និង/ឬស្វ័យភាពរបស់មន្ត្រីខ្មែរក្រហមថ្នាក់ទាប។ ករណីនេះជារឿងពាក់ព័ន្ធដែលមិនអាចប្រកែកបានដើម្បីបដិសេធចោលរាល់កម្រិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលគេដាក់មកលើលោក **នួន ជា** ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញា ("កសព") ។ ក្នុងន័យនេះ អត្ថាធិប្បាយរបស់ **ហោ ណាំហុង** ពិតជាមានផលប៉ះពាល់ ទោះបីជាមិនមានបំណងជាក់លាក់ដើម្បីបង្អាក់ដល់ការព្យាយាមរបស់មេធាវីការពារក្តីក្នុងការវាយតម្លៃអំពីកម្រិតនៃការទទួលខុសត្រូវរបស់មន្ត្រីថ្នាក់ក្រោមក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ហើយបើនិយាយមួយបែបទៀត គឺវាប៉ះពាល់ដល់

---

តែប៉ុណ្ណោះ។ លោក ស៊ីផាន បានឲ្យដឹងទៀតថា" ជា ស៊ីម និង ហេង សំរិន មិនមែនជាមេដឹកនាំជាន់ខ្ពស់ទៅនៅពេលនោះទេ "។ លោកបានបន្ថែមទៀតថា ជាងនេះទៅទៀត លោក ស៊ីម និងលោក សំរិន ឥឡូវនេះជាមេដឹកនាំរបស់រដ្ឋាភិបាលកម្ពុជាដែលទទួលបានការគោរព និងគាំទ្រពីប្រជាជន ពួកគាត់មិនមែនជាឧក្រិដ្ឋជនឡើយ។ លោកបានអះអាងទៀតថា "ប្រជាជនកម្ពុជា (ភាគច្រើន).. បោះឆ្នោតឲ្យ ជា ស៊ីម និង ហេង សំរិន។ ពួកគេមិនបានបោះឆ្នោតឲ្យ នួន ជា ទេ"។ អ្នកនាំពាក្យរូបនេះបានបន្ថែមទៀតថា Jasper Pauw គួរតែផ្តោតតែលើការការពារកូនក្តីរបស់ខ្លួនបានហើយ។ ស៊ីផាន បាននិយាយថា "ពួកគេមិនគួរធ្វើការចោទប្រកាន់នរណាម្នាក់ឡើយ។ វាមិនបានជួយដល់កូនក្តីរបស់គាត់ទេ", កាសែត ខឺ ឃែមបូឌា ដេលី, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ដោយ Alice Foster និង Phorn Bopha, "រដ្ឋាភិបាលបដិសេធការអះអាងដែលបានធ្វើឡើងនៅសាលាក្តីខ្មែរក្រហម" ដកស្រង់ចេញពី *Cambodia Daily* ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ទំព័រទី១។ ពិតណាស់ ជា ស៊ីម និង ហេង សំរិន ត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួនចំពោះសហចៅក្រមស៊ើបអង្កេតតាមសំណើរបស់មេធាវីការពារក្តី ដើម្បីរៀបរាប់ពីប្រវត្តិនៃព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច ហោ ណាំហុង ដែរ ពួកគេចូលចិត្តបញ្ចោក់ពីគោលជំហររបស់ពួកគេតាមប្រព័ន្ធផ្សព្វផ្សាយតាមរយៈអ្នកនាំពាក្យ ហើយមើលរំលងដីកាកោះរបស់ កសចស។

[22] សូមមើលឯកសារ **E-131/2.1.1**, បណ្តឹងព្រហ្មទណ្ឌ, ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១, ERN 00749616–00749624។

ការប្រឹងប្រែងរបស់មេធាវីការពារក្តី*ក្នុងការស្វែងរកការពិត*[23]។ បញ្ហានេះ បង្កើតបានជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។

១៩. លើសពីនេះទៅទៀត ការលើកឡើងដែលថាគេគ្មានតំណែលខ្មែរក្រហមមិនអាចការពារបាន បានបង្ហាញថា មេដឹកនាំខ្មែរក្រហម មិនសមទទួលបានការការពារក្តី[24] បង្កើតបានជាជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់ **នួន ជា** ដែលត្រូវគេសន្មតទុកជាមុនថាគ្មានទោស ហើយដូច្នេះវាផ្ទុយទៅនឹងវិធានដែលមានចែងក្នុងរឿងក្តី Ribemont[25] ដែលជាផ្នែកមួយនៃយុត្តិសាស្ត្រអន្តរជាតិ ដែលថ្មីៗនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា អាចយកមកអនុវត្តដោយផ្ទាល់ចំពោះការអត្ថាធិប្បាយជាសាធារណៈរបស់មន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងដំណើរការនីតិវិធីកំពុងបន្តក្នុងសំណុំរឿង០០២[26]។ តាមពិតទៅ ដោយសារហេតុផលដូចគ្នាដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុងសំណើសុំចំណាត់ការបន្ទាន់ប្រឆាំង ហ៊ុន សែន[27] សេចក្តីថ្លែងការណ៍នេះ គឺស្មើនឹងការរំលោភសិទ្ធិជាមូលដ្ឋានបំផុតរបស់ **នួន ជា** ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា។ ដូច្នេះ ទឡ្ហីករណ៍ដែលមេធាវីការពារក្តីលើកឡើងកាលពីមុន ត្រូវបានដាក់បញ្ចូលតាមការកែប្រែចាំបាច់ (*mutatis*

---

[23]ពិតណាស់ ការអត្ថាធិប្បាយនេះស៊ីសង្វាក់គ្នាទៅនឹងការព្យាយាមយ៉ាងច្បាស់ក្រឡែតរបស់រដ្ឋាភិបាលបច្ចុប្បន្ន ដើម្បីដាក់ឱ្យមេដឹកនាំខ្មែរក្រហមបួនរូបដែលកំពុងជំនុំជម្រះក្តីនៅពេលឥឡូវនេះ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបញ្ហានេះត្រូវបានបង្ហាញយ៉ាងច្បាស់បំផុតតាមរយៈគោលជំហររបស់រដ្ឋាភិបាលកម្ពុជាលើការចោទប្រកាន់បន្ថែមប្រឆាំងនឹងមន្ត្រីខ្មែរក្រហមបន្ថែមទៀតក្នុងសំណុំរឿង ០០៣ និង ០០៤ ។ ដូចដែលបានលើកឡើងដោយសាស្ត្រាចារ្យ David Chandler ថា ការរៀបរាប់អំពីមេដឹកនាំដ៏ឃោរឃៅមួយចំនួន និងអ្នកដែល សេសសល់នៅក្នុងប្រទេសដែលជាជនរង គ្រោះដែលគ្មានកំហុស ត្រូវតែមានការគាំទ្រយ៉ាងពេញទំហឹងសំរាប់មូលហេតុដ៏មិនគួរអោយជឿសំរាប់ប្រសិទ្ធិភាពនយោបាយ។

។ ក្នុងន័យនេះដែរ "ភាមចម្រុងចម្រះ" ដែល ហោ ណាំហុង មានបំណងគេចវេស (មើលសេចក្តីថ្លែងការ) ហាក់បីដូចជាបុគ្គលម្នាក់ចេញពី "ប្រវត្តិពិត"ជាផ្លូវការ ដែលថា ហោ ណាំហុង តែងតែត្រូវបានការពារដោយរដ្ឋាភិបាល និងនៅមុនពេលនោះ គឺជាមន្ត្រីរបស់សម័យសាធារណៈរដ្ឋកម្ពុជា (ដែលជាបុគ្គលដូចគ្នា)។

[24] សូមមើលកថាខណ្ឌទី២, ដូចដើងទំព័រខាងលើ។

[25] សូមមើលសំណើសុំឱ្យមានចំណាត់ការបន្ទាន់ប្រឆាំងលោក ហ៊ុន សែន, ទំព័រ ១២ ដល់១៣។

[26] សូមមើលសំណើសុំឱ្យមានចំណាត់ការបន្ទាន់ប្រឆាំង ហ៊ុន សែន, ទំព័រ ១៧។

[27] សូមមើលសំណើសុំឱ្យមានចំណាត់ការបន្ទាន់ប្រឆាំងហ៊ុន សែន, ទំព័រ ១៧ ដល់២០។

*mutandis)* ។ ដូចគ្នានឹងការអធិប្បាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរឿងក្តី *Ribemont* ដែរ ការថ្លែងជាសាធារណៈរបស់ **ហោ ណាំហុង** គឺ "ផ្ទុយនឹងការសន្មតជាមុនថាគ្មានទោស[28]"។

២០. នៅចុងបញ្ចប់ ខណៈពេលដែល **ហោ ណាំហុង** ជាពលរដ្ឋកម្ពុជាម្នាក់អាចបញ្ចេញទស្សនៈ និងការអង្កេតរបស់គាត់ដោយសេរីទាក់ទងនឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់នោះ ហើយក្នុងនាមជារដ្ឋមន្ត្រីម្នាក់ក្នុងរាជរដ្ឋាភិបាលកម្ពុជា គាត់ត្រូវចងដោយរចនាសម្ព័ន្ធច្បាប់ មិនថាឡើយគាត់ពេញចិត្តវា ឬអត់នោះទេ[29]។ ពិចារណាលើតួនាទីរបស់គាត់ដែលជារដ្ឋមន្ត្រីម្នាក់ គាត់ពិតជាមិនមានសេរីភាពក្នុងការផ្តល់វោហាសាស្ត្រដោយកំបាំង និងចំហនោះទេដែលប៉ះពាល់ដល់ដំណើរការតុលាការនៅចំពោះមុខអ្នកអង្កេតការដែលឥតលម្អៀង និងទទួលបានព័ត៌មានពាក់ព័ន្ធគ្រប់គ្រាន់។ [ច្បាប់តម្រូវឲ្យមន្ត្រីប្រតិបត្តិនិយាយជាសាធារណៈអំពីសំណុំរឿងឧក្រិដ្ឋកម្មដែលកំពុងបន្ត] ជាមួយឆន្ទានុសិទ្ធិ និងភាពប្រយ័ត្នប្រយែងទាំងអស់ដែលចាំបាច់" ដើម្បីគោរពសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[30]។ ជាអកុសលការថ្លែងនាពេលថ្មីៗនេះដោយលោករដ្ឋមន្ត្រីការបរទេស ហួសពីដែនកំណត់នៃការថ្លែងដែលអាចទទួលយកបានសម្រាប់មនុស្សក្នុងមុខតំណែងនេះ ហើយវារំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ **នួន ជា**។

២១. និយាយដោយខ្លីទៅ ការអះអាងក្នុងសេចក្តីថ្លែងការណ៍ដែលថា អវតក "គឺជាតុលាការច្បាប់មិនមែនជាវេទិកានយោបាយ" និងថា "ការប៉ុនប៉ងធ្វើឲ្យតុលាការនេះក្លាយជារឿងនយោបាយ ឬបង្កឲ្យមានភាពចម្រូងចម្រាស គឺជារឿងមិនត្រឹមត្រូវ" គឺពិតជាសំដីព្រហើន (*chutzpah*) បើយើងពិនិត្យទៅលើការជ្រៀតជ្រែកដែលចេះតែបន្ត និងដែលត្រូវបានកត់ត្រាទុកជាឯកសារត្រឹមត្រូវនិងមិនអាចប្រកែកបានពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាទៅក្នុងកិច្ចការរបស់ អវតក ។

### គ. អង្គជំនុំជម្រះត្រូវផ្តល់ដំណោះស្រាយដែលអាចអនុវត្តបាន និងមានប្រសិទ្ធភាព

---

[28] រឿងក្តី Ribemont តទល់ប្រទេសបារាំង, ECHR ពាក្យសុំលេខ 15175/89 ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ នៅកថាខណ្ឌ៣៨ ។

[29] ដោយមិនបានបញ្ជាក់ពីបញ្ហាណាមួយឲ្យពិតប្រាកដ គេចាំបាច់ត្រូវធ្វើការកត់សម្គាល់ថា ចំណងជើងពេញលេញនៃការថ្លែងនេះគឺជា ***មតិយោបល់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី*** ហោ ណាំហុង ***រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*** (គូសបញ្ជាក់បន្ថែម)។

[30] ដូចគ្នាកថាខណ្ឌ ៣៨។

២២. ដើម្បីទប់ស្កាត់ព្យសនកម្មបន្ថែមទៀត ការថ្កោលទោសជាសាធារណៈទៅលើការកត់សម្គាល់របស់ **ហោ ណាំហុង** និងការព្រមានជាសាធារណៈថា ការធ្វើអធិប្បាយបន្ថែមនឹងទទួលរងនូវវិធានការម៉ឺងមាត់ គឺជាដំណោះស្រាយសមស្របនៅដំណាក់កាលនេះ។ មិនតែប៉ុណ្ណោះអង្គជំនុំជម្រះនេះមិនត្រឹមតែមានភារកិច្ចជាវិជ្ជមានក្នុងការថ្កោលទោសសកម្មភាពនានា ដែលជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលនោះទេ តែក៏មិនត្រូវរួញរាពន្យល់ដល់រដ្ឋមន្ត្រីការបរទេស និងមហាជនថានៅក្នុងសង្គមប្រជាធិបតេយ្យតុលាការមិនស្វាគមន៍ការណែនាំពីអង្គនីតិប្រតិបត្តិទេ។ ដូចដែលបានលើកឡើងរួចមកហើយ អង្គជំនុំជម្រះត្រូវបង្ហាញឯករាជ្យភាព សមត្ថភាពរបស់ខ្លួន និងការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការជំនុំជម្រះដោយយុត្តិធម៌ដល់ **នួន ជា**។ ប្រសិនបើកម្ពុជា គឺជាសង្គមបើកចំហពិតប្រាកដដូចដែលអះអាងដោយមន្ត្រីនានានៃរដ្ឋាភិបាល នោះប្រធានអង្គជំនុំជម្រះ និងសមាសភាគីរបស់គាត់មិនត្រូវរួញរាក្នុងការចាត់វិធានការដែលទទួលយកបាន គឺរិះគន់ខ្លាំងៗដល់ **ហោ ណាំហុង** និងការអធិប្បាយរបស់គាត់ដែលបង្កការអន្តរាយ ។

## V. **សេចក្តីសន្និដ្ឋាន**

២៣. អាស្រ័យដូចមូលហេតុដែលបានបញ្ជាក់នៅទីនេះ អង្គជំនុំជម្រះគប្បី:

ក. ទទួលយកសំណើនេះ

ខ. ទទួលស្គាល់ថាការអធិប្បាយរបស់ **ហោ ណាំហុង** ចាត់ជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលនៅ អវតក

គ. ចាត់ចំណាត់ការបន្ទាន់ដោយស្តីបន្ទោសជាសាធារណៈដល់រដ្ឋមន្ត្រីការទេស និងព្រមានគាត់ជាផ្លូវការមិនឲ្យធ្វើការធ្វើអធិប្បាយបែបនេះតទៅទៀត ។

សូមស្នើដាក់អំណះអំណាងផ្ទាល់មាត់នៅសវនាការសាធារណៈនៅមុនការសម្រេចណាមួយ ។

**សហមេធាវីការពារក្តីលោក នួន ជា**

Michiel PESTMAN    Jasper PAUW    Andrew IANUZZI